ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អអក
EAC
អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ៤៩៥-សណ-១៧ អអក

ភ្នំពេញ, ថ្ងៃទី២៨ ខែ កក្កដា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
## ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់ក្រុមហ៊ុន អ៊ី.ឌី.ខន សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកពញាក្រែក ស្រុកត្បូងឃ្មុំ ស្រុកក្រូចឆ្មារ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ និងស្រុកកំចាយមារ ខេត្តព្រៃវែង

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជនរស់នៅក្នុងឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់ក្រុមហ៊ុន អ៊ី.ឌី.ខន ដើម្បីអនុញ្ញាតឲ្យដកតំបន់រដ្ឋបាលខេត្តត្បូងឃ្មុំ ចេញពីតំបន់ចែកចាយដែលមានស្រាប់ តាមខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណដូចមានជូនភ្ជាប់មកជាមួយនេះ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជន មានសិទ្ធិពិនិត្យ ផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា លើខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណដែលគ្រោងផ្តល់ជូនក្រុមហ៊ុន អ៊ី.ឌី.ខន ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណនៅ........................................................................................................ សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជនរស់នៅក្នុងឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណក្រុមហ៊ុន អ៊ី.ឌី.ខន អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះរហូតដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា **"អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ"** ។ល។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ឆី នរិន្ទ**

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

**សេចក្តីព្រាង**

# អាជ្ញាធរអគ្គិសនីកម្ពុជា

ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

ELECTRICITY LAW OF THE KINGDOM OF CAMBODIA

## សេចក្តីសម្រេចកែសម្រួលលើកទី៦

**លើឯកសារអាជ្ញាបណ្ណលេខ ១២២ ឯអ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៥ សម្រាប់ក្រុមហ៊ុន អ៊ី.ឌី.ខន ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកពញាក្រែក ស្រុកត្បូងឃ្មុំ ស្រុកក្រូចឆ្មារ និងស្រុកតំបែរ ខេត្តត្បូងឃ្មុំ និងស្រុកកំចាយមារ ខេត្តព្រៃវែង**

**សម្រាប់ការដកតំបន់ចែកចាយ**

## DECISION ON THE SIXTH REVISION

OF THE LICENSE DOCUMENT No.122 LD DATED DECEMBER 28, 2005 OF E.D.CON CO., LTD FOR PROVIDING ELECTRIC POWER SERVICE AT SOME PART OF PONHEA KREK, TBONG KHMUM, KROUCH CHHMAR AND TAMBE DISTRICTS, TBONG KHMUM PROVINCE AND KAMCHAYMEAR DISTRICT, PREY VENG PROVINCE

**FOR WITHDRAWING DISTRIBUTION AREA**

ថ្ងៃទី ខែ ឆ្នាំ២០១៧

.. .., 2017